# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៚

# កិច្ចព្រមព្រៀង

## រវាង

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## និង

## អង្គការ មូលនិធិហាការអន្តរជាតិ

## ស្តីពី

***“ការផ្លាស់ប្តូរឥរិយាបថបុគ្គលនិងសហគមន៍ដើម្បីលើកកម្ពស់សុវត្ថិភាពជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស”***

# បុព្វកថា

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសម្តែងនូវបំណងប្រាថ្នាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង នៃការយោគយល់នេះថា អង្គការមូលនិធិហាការអន្តរជាតិ បានរួមចំណែកក្នុងការលើកកម្ពស់វិស័យសេដ្ឋកិច្ចសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទនិងអំពើហិង្សាធ្ងន់ធ្ងរផ្អែកយេនឌ័រ ព្រមទាំងពលករចំណាកស្រុកដែលបានធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ ក៏ដូចជាការលើកកម្ពស់ការយល់ដឹងឲ្យកាន់តែប្រសើរឡើងអំពីការគោរពសិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជាដែលកំពុងធ្វើការនៅក្នុង និងក្រៅប្រទេស ដើម្បីការពារ និងឆ្លើយតបបញ្ហាទេសន្តរប្រវេសន៍ប្រកបដោយប្រសិទ្ធភាព។

**ដោយយល់ថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការមូលនិធិហាការអន្តរជាតិតាមរយៈកិច្ចសហប្រត្តិបត្តិការដើម្បីបង្ការទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ និងការពារប្រកបដោយប្រសិទ្ធភាព ចំពោះការរំលោភបំពាន ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងអំពើជួញដូរមនុស្សគ្រប់រូបភាព ។

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការមូលនិធិហាការអន្តរជាតិ បានព្រមព្រៀងសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដោយផ្អែកលើផែនការយុទ្ធសាស្ត្រជាតិ (គ.ជ.ប.ជ ២០១៩-២០២៣) ច្បាប់ គោលនយោបាយជាតិ និងអន្តរជាតិ ព្រមទាំងបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា និងអន្តរជាតិ ដើម្បីពង្រឹងសកម្មភាពលើកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ ការសង្គ្រោះ ការផ្តល់សេវាជូនជនរងគ្រោះ និងការលើកកម្ពស់ការយល់ដឹង អំពីសុវត្ថិភាពនៃការធ្វើទេសន្តរប្រវេសន៍ការងារឲ្យមានប្រសិទ្ធភាពខ្ពស់ ។

## ប្រការ១

### គោលបំណង

កិច្ចព្រមព្រៀងនេះ មានគោលបំណងផ្តល់អត្ថប្រយោជន៍ដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ អំពើហិង្សាផ្អែកលើយេនឌ័រ ក៏ដូចជាពលករចំណាកស្រុកដែលបានធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ និងសហគមន៍ដែលគាត់រស់នៅ (ក្នុងតំបន់គោលដៅដែលបានជ្រើសរើស) ជាពិសេស ក្នុងស្ថានភាពដែលទទួលរងផលប៉ះពាល់ដោយសារជំងឺកូវីដ១៩ ឲ្យមានលទ្ធភាពលើកកម្ពស់ស្ថានភាព និងជីវភាពក្នុងការរស់នៅ ឲ្យប្រសើរឡើង តាមរយៈការផ្លាស់ប្តូរទស្សនៈ និងឥរិយាបថដែលអវិជ្ជមាន មិនរីកចម្រើន ឲ្យទៅជារបៀបរស់នៅដែលមានភាពរីកចម្រើន ប្រកបដោយសុវត្ថិភាព និងសុខុមាលភាពសង្គម និង បញ្ចៀសបានពីភាពរងគ្រោះជាថ្មី ។

## ប្រការ២

### ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

ដើម្បីឲ្យការអនុវត្តកិច្ចព្រមព្រៀងនេះទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានព្រមព្រៀងដូចខាងក្រោម៖

- អនុញ្ញាតឲ្យអង្គការមូលនិធិហាការអន្តរជាតិ បំពេញការងាររបស់ខ្លួន ទៅតាមគោលការណ៍ច្បាប់ និង បទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន
- សម្របសម្រួលកិច្ចសហការ ជាមួយគណៈកម្មាធិការរាជធានី-ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ/គ.ខ.ប.ជ) និងអ្នកពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមសហការជាមួយអង្គការមូលនិធិហាការអន្តរជាតិ ដើម្បីអនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងតួនាទី ភារកិច្ច របស់ក្រុមការងាររបស់គ.រ.ប.ជ និងគ.ខ.ប.ជ នៅសហគមន៍ ដើម្បីប្រសិទ្ធភាពការងារ
- រៀបចំកិច្ចប្រជុំបច្ចេកទេសរៀងរាល់ ០៣ខែម្តង ដើម្បីតាមដានភាពរីកចម្រើនក្នុងការអនុវត្តគម្រោង ភាពប្រឈមដែលត្រូវដោះស្រាយ និងចែករំលែកនូវបទពិសោធន៍នានា ដែលទទួលបានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីបង្ការទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ និងការពារជនរងគ្រោះប្រកបដោយប្រសិទ្ធភាព និងដាក់បញ្ចូលលទ្ធផលនៃកិច្ចសហការរវាង គ.ជ.ប.ជ និងអង្គការមូលនិធិហាការអន្តរជាតិ ទៅក្នុងទិន្នន័យថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ គ.ជ.ប.ជ ។
- ចាត់តាំងមន្ត្រីជំនាញដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពសមស្រប ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យបំពេញការងារជាមួយអង្គការមូលនិធិហាការអន្តរជាតិ ដើម្បីឲ្យសកម្មភាពគម្រោងអនុវត្តទៅមានប្រសិទ្ធភាព និងទាន់ពេលវេលា ។
- អនុញ្ញាតឲ្យអង្គការមូលនិធិហាការអន្តរជាតិអាចជួលបុគ្គលិកធ្វើការបាន ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត របស់ព្រះរាជាណាចក្រកម្ពុជា ។
- អនុញ្ញាតឲ្យគណៈកម្មាធិការរាជធានី-ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ/គ.ខ.ប.ជ) ធ្វើការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអង្គការមូលនិធិហាការអន្តរជាតិ ដើម្បីកសាងផែនការសកម្មភាព គ្រប់គ្រង និងដោះស្រាយបញ្ហារួមគ្នា ។
- សហការបង្កើតសម្ភារ ឧបករណ៍ និងបណ្តុះបណ្តាលមន្ត្រីជំនាញ បម្រើឱ្យវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធក្នុងគម្រោង និងប្រតិបត្តិករនានា តាមប្រភេទនៃជំនាញ និងបម្រើឱ្យសកម្មភាពតាមដានត្រួតពិនិត្យ ។
- អនុញ្ញាតឲ្យអង្គការមូលនិធិហាការអន្តរជាតិ ចូលរួមពិភាក្សាជាមួយក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័ន តាមការចាំបាច់ និងជាមួយក្រុមជំនាញនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងការរៀបចំដំណើរការគម្រោងសកម្មភាព និងបទដ្ឋានការងារផ្សេងៗ ដើម្បីធ្វើឲ្យសម្រេចនូវគោលបំណងនៃកិច្ចព្រមព្រៀងនេះ ។
- បង្កើតសម្ភារ ឯកសារ ផ្សេងៗបម្រើឲ្យគម្រោង ដែលជាស្នាដៃរួមគ្នារវាង គ.ជ.ប.ជ និងអង្គការមូលនិធិហាការអន្តរជាតិ និងអាចចែកផ្សាយទៅដៃគូដទៃ តាមការចាំបាច់ ។
- ពិនិត្យលទ្ធភាព ដើម្បីពង្រីកសកម្មភាពទៅគោលដៅផ្សេងទៀត តាមការចាំបាច់ ។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងសកម្មភាពនានា ដែលបានអនុវត្តក្រោមកិច្ចព្រមព្រៀងនេះ និងជួយកែលម្អ ដើម្បីធ្វើឲ្យទទួលបានលទ្ធផលតាមការរំពឹងទុក ។

## ប្រការ៣

### ការទទួលខុសត្រូវរបស់អង្គការមូលនិធិហាការអន្តរជាតិ

អង្គការមូលនិធិហាការអន្តរជាតិមានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

**ក. ការអនុវត្តគម្រោង**

- គោរពយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឲ្យភ្នាក់ងាររបស់ខ្លួន ចូលរួមនូវរាល់សកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្ដាប់ធ្នាប់សង្គម ឬសកម្មភាពល្មើសច្បាប់ដទៃទៀតឡើយ
- ចូលរួម ពិភាក្សា ដើម្បីជ្រើសរើសក្រុមគោលដៅ តំបន់គោលដៅ និងរៀបចំដំណើរការសកម្មភាពរួមគ្នាជាមួយអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ដោយគាំទ្រមូលនិធិដល់សកម្មភាពដែលបានគ្រោងទុកក្នុងគម្រោងក្រោមកិច្ចព្រមព្រៀងនេះឲ្យបានសមស្រប
- ចូលរួមធ្វើផែនការសកម្មភាព និងគាំទ្រសកម្មភាពអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងលេខាធិការដ្ឋាន គ.ខ.ប.ជ និង គ.រ.ប.ជ ដែលពាក់ព័ន្ធនឹងគម្រោង ក្រោមកិច្ចព្រមព្រៀងនេះ
- ចូលរួមសហការជាមួយ គ.ជ.ប.ជ ដើម្បីបង្កើតសម្ភារ ឧបករណ៍ និងបណ្តុះបណ្តាលមន្ត្រីជំនាញ បម្រើឱ្យវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធក្នុងគម្រោង និងប្រតិបត្តិករនានា តាមប្រភេទនៃជំនាញ និងបម្រើឱ្យសកម្មភាពតាមដាន ត្រួតពិនិត្យ ។
- ផ្តល់ចំណេះដឹងចាំបាច់ សំខាន់ៗ ដល់អាជ្ញាធរមូលដ្ឋាន និងស្ថាប័ននានា ពាក់ព័ន្ធនឹងជំនាញ ក្នុងការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចគ្រប់រូបភាព អំពើហិង្សាផ្អែកលើយេនឌ័រ ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងកិច្ចការពារការឆ្លងរីករាលដាលនូវជំងឺកូវីដ១៩ ដោយគាំទ្រ ទាំងស្មារតី សម្ភារ ថវិកាតាមការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តសកម្មភាពទាំងនេះ រហូតចប់គម្រោង
- ផ្តល់ចំណេះដឹង និងជួយលើកកម្ពស់ ការផ្លាស់ប្តូរឥរិយាបថ និងទម្លាប់ក្នុងការរស់នៅដែលមិនជឿនលឿនឲ្យទៅជាការរស់នៅដែលមានអនាម័យ មានភាពរីករាយ មានការយកចិត្តទុកដាក់ថែទាំសុខភាពផ្លូវកាយផ្លូវចិត្តផ្ទាល់ខ្លួននិងគ្រួសារ និងចេះការពារខ្លួន គ្រួសារ និងសហគមន៍ពីការឆ្លងរាលដាលដោយជំងឺកូវីដ១៩ និងជំងឺឆ្លងដទៃទៀត
- ផ្តល់ការគាំទ្រទាំងស្មារតី សម្ភារ និងមូលនិធិចាំបាច់ ដែលអាចទ្រទ្រង់ជនគោលដៅ សមាជិកគ្រួសារ រួមទាំងជនចំណាកស្រុកដែលវិលត្រឡប់ គ្រប់ស្ថានភាព ជាពិសេស អ្នកដែលរួចផុតពីភាពរងគ្រោះនានា និងសហគមន៍ដែលគាត់រស់នៅ ឲ្យទទួលបាននូវឱកាសបង្កើនសេដ្ឋកិច្ចគ្រួសារ និងការរីកចម្រើនក្នុងសហគមន៍ ដោយផ្លាស់ប្តូររបត់ក្នុងការរស់នៅ ទស្សនៈដែលអវិជ្ជមានមិនរីកចម្រើន ទម្លាប់ដែលប្រថុយប្រថាននឹងគ្រោះថ្នាក់ ការប្រព្រឹត្តអំពើហិង្សា ឲ្យចេះគិត ចេះពិចារណា ចេះប្រាស្រ័យទាក់ទងគ្នា និងសហការគ្នារកភាពរីកចម្រើន ចេះរកចំណូលដោយសុចរិត គោរពច្បាប់ គោរពការណែនាំ ចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ភូមិ ឃុំ និងរួមគ្នាធ្វើឲ្យភូមិឃុំ សង្កាត់ មានសុវត្ថិភាព ។ល។

- សហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សថ្នាក់ជាតិ(គ.ជ.ប.ជ) និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) ជាដៃគូការងារដើម្បីជំរុញសកម្មភាពឲ្យទទួលបានលទ្ធផលកម្រិតខ្ពស់ ក្នុងការផ្ទេរនិងពង្រឹងជំនាញបច្ចេកទេសទៅមន្ត្រី និងប្រតិបត្តិករនៅតាមសហគមន៍
- រាល់ការបោះពុម្ព ឬឯកសារទាំងឡាយណា ដែលបានពីសមិទ្ធផលរបស់គម្រោងនេះ ត្រូវបានដាក់ជូន គ.ជ.ប.ជ និង គ.ខ.ប.ជ/គ.រ.ប.ជ ផ្តល់យោបល់ រួចហើយនឹងត្រូវចាត់ទុកថាជាសមិទ្ធផលការងាររួម របស់អង្គការមូលនិធិហាការអន្តរជាតិ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ចូលរួមឲ្យបានទៀងទាត់រាល់កិច្ចប្រជុំ តាមការអញ្ជើញរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និង លេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ ដើម្បីសម្របសម្រួលសកម្មភាពរបស់គម្រោងដែលកំពុងដំណើរការ ព្រមទាំងធ្វើការផ្លាស់ប្តូរព័ត៌មាន ដើម្បីឈានទៅសម្រេចជោគជ័យតាមទិសដៅរបស់គម្រោង
- រាយការណ៍ពីព័ត៌មាននានាដែលទទួលបានពីក្រុមការងារជំនាញ និងសហគមន៍ ជូនទៅដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងថ្នាក់ក្រោមជាតិជាប្រចាំ
- ផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងថ្នាក់ក្រោមជាតិ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងម្ចាស់ជំនួយ តាមកាលកំណត់ ។

**ខ. អំពីការគ្រប់គ្រង និងចាត់ចែងមូលនិធិ**

- ជំនួយរបស់អង្គការមូលនិធិហាការអន្តរជាតិ ជាជំនួយសម្រាប់ឧបត្ថម្ភចំពោះគម្រោងនៃកម្មវិធីមនុស្សធម៌សុទ្ធសាធ ហើយអង្គការនេះ នឹងមិនប្រើប្រាស់ជំនួយនេះក្នុងគោលបំណង បម្រើនយោបាយ សាសនា ឬយោធាឡើយ
- អង្គការមូលនិធិហាការអន្តរជាតិ ទទួលបន្ទុកគ្រប់គ្រង ចាត់ចែងថវិកា ដែលទទួលបានការគាំទ្រពីម្ចាស់ជំនួយនានា ដោយផ្ទាល់ខ្លួនឯង ដើម្បីជានាបម្រើដល់ការអនុវត្តសកម្មភាពរបស់គម្រោងឲ្យមានប្រសិទ្ធភាព ចំគោលដៅ ប្រកបដោយការទទួលខុសត្រូវ
- គម្រោងថវិកាដែលបានអនុម័ត ត្រូវប្រើប្រាស់ឲ្យមានប្រសិទ្ធភាពតាមទិសដៅដូចបានកំណត់ (សរុបចំណាយមិនផ្ទាល់ មិនត្រូវលើសពី ២៥% នៃចំណាយសរុប)។

សេចក្តីសង្ខេបអំពីគម្រោង និង សកម្មភាពជាក់ស្តែងរបស់អង្គការហាការអន្តរជាតិ សហការជាមួយ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ ដែលអង្គការហាការ ត្រូវប្រតិបត្តិ មានចែងលម្អិតក្នុងឧបសម្ព័ន (១) (២) និង (៣) ។

**គ. អំពីសុពលភាពកិច្ចព្រមព្រៀង និងគម្រោងនានាក្រោមកិច្ចព្រមព្រៀង**

- ក្នុងរយៈពេល០៦ខែ បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះជាផ្លូវការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរួចមក ប្រសិនបើអង្គការមូលនិធិហាការអន្តរជាតិ ពុំបានអនុវត្តតាមការកំណត់ដែលមានចែងក្នុងប្រការ៣ នៃកិច្ចព្រមព្រៀងនេះដោយមិនមានហេតុផលសមស្រប កិច្ចព្រមព្រៀងនេះនឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្ត ហើយអង្គការមូលនិធិហាការអន្តរជាតិ នឹងមិនទទួលបានសិទ្ធិក្នុងការបន្តអនុវត្តគម្រោងសកម្មភាពនេះ បន្តទៀតឡើយ។

- ជូនដំណឹងមក គ.ជ.ប.ជ ជាលាយលក្ខណ៍អក្សរ ក្នុងករណីដែលអង្គការផ្លាស់ប្តូរអាសយដ្ឋាន ប្រធានអង្គការ ឬគម្រោងកម្មវិធី លេខទូរស័ព្ទ និងទូរសារទំនាក់ទំនង។
- ចំពោះករណីមានការនាំចូលឧបករណ៍ និងសម្ភារដែលយកមកប្រើប្រាស់គាំទ្រឲ្យសកម្មភាពគម្រោង អង្គការត្រូវជូនដំណឹងមក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមពេលវេលាសមស្របមុនពេលដែលឧបករណ៍សម្ភារគ្រោងនាំចូលមកដល់ ហើយត្រូវអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ៤.

### ការដោះស្រាយវិវាទ

វាល់វិវាទដែលអាចកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ គ.ជ.ប.ជ និង អង្គការមូលនិធិហាការអន្តរជាតិ ត្រូវដោះស្រាយតាមរយៈការចរចាដោយសន្តិវិធី រវាងភាគីទាំងពីរ ។

## ប្រការ ៥.

### អវសានប្បញ្ញត្តិ

កិច្ចព្រមព្រៀងនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និង មានសុពលភាពរយៈពេល៣(បី)ឆ្នាំ ហើយអាចបន្តសុពលភាពបានទៀតដោយមានការយល់ព្រមពីភាគីទាំងពីរ។

ភាគីម្ខាងអាចជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ ក្នុងពេលណាក៏បាន ប្រសិនបើខ្លួនមានបំណងបញ្ចប់កិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមព្រៀង នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង ។

កិច្ចព្រមព្រៀងនេះ ធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងពីរភាសាមានតម្លៃស្មើគ្នា ។ ក្នុងករណីមិនមានការឯកភាពគ្នាលើការបកស្រាយអត្ថបទទាំងនេះ អត្ថបទជាភាសាខ្មែរត្រូវយកជាគោល ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......15......ខែ.....វិច្ឆិកា...ឆ្នាំ ២០២១

| | |
|---|---|
| **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)** | **តំណាងអង្គការមូលនិធិហាការអន្តរជាតិ** |
| **អនុប្រធានអចិន្ត្រៃយ៍** | **នាយកប្រតិបត្តិប្រចាំប្រទេស** |
| **លោកជំទាវ ជូ ប៊ុនអេង** | **លោកស្រី កែវ គៀង** |

# ឧបសម្ព័ន្ធ(១)

## សង្ខេបអំពីគម្រោង

"ការលើកកម្ពស់ និងពង្រឹងអំណាចទៅលើវិស័យសេដ្ឋកិច្ចគ្រួសារសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទនិងអំពើហិង្សាធ្ងន់ធ្ងរផ្នែកយេនឌ័រនៅក្នុងចំណោមពលករចំណាកស្រុកដែលបានធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជា"

**ឈ្មោះស្ថាប័នអនុវត្តគម្រោង៖** អង្គការ មូលនិធិហាកាអន្តរជាតិ

**ប្រភេទស្ថាប័ន៖** អង្គការអន្តរជាតិ

បានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០២០

**អាសយដ្ឋានរបស់ស្ថាប័ន៖** ផ្ទះលេខ ២១៨A, ផ្លូវលេខ៥៩០, ភូមិទួលសំពៅ, សង្កាត់ទួលសង្កែទី១, ខណ្ឌឫស្សីកែវ, រាជធានីភ្នំពេញ

*លេខទូរស័ព្ទទំនាក់ទំនង៖* (៨៥៥)២៣ ៤២៤ ៦៦៤ ឬ (៨៥៥)៦៧ ៧៣៧ ៧៧២

*អ៊ីម៉ែល៖* cambodia@hagarinternational.org ឬ keang.keo@hagarinternational.org

*ប្រអប់សំបុត្រ៖* ១៥២១

*អាសយដ្ឋានរបស់ការិយាល័យខេត្តបាត់ដំបងដែលអនុវត្តគម្រោង៖* ផ្ទះលេខ G14 ផ្លូវប៉ៃលិន ភូមិដំណាក់ហ្លួង សង្កាត់វត្តគរ ក្រុមទី៤ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

*ទីកន្លែងអនុវត្តគម្រោង៖* ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ, ខេត្តប៉ៃលិន និង ខេត្តសៀមរាប

*អាសយដ្ឋានការិយាល័យនៅ៖* ប្រទេសស្វីស Switzerland/ZUG: ZUG, c/o reichlin Hess AG, Hofstrasse 1A, 6300 Zug, អ៊ីម៉ែល៖ peter.hess@reichlinhess.ch

**ថិរវេលារបស់គម្រោង** ៖ ០៣ឆ្នាំ

កាលបរិច្ឆេទចាប់ផ្តើម ៖ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១ (បានចុះកិច្ចសហការនៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២១)

កាលបរិច្ឆេទបញ្ចប់ ៖ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០២៤

*ថវិកាគម្រោងសរុប* ៖ USD*៦២៥,000.00* ដុល្លារអាម៉េរិក (ប្រាំមួយរយម្ភៃប្រាំពាន់ដុល្លារអាម៉េរិក)

*អ្នកផ្តល់ថវិកាគាំទ្រគម្រោង* ៖

| ឈ្មោះស្ថាប័នផ្តល់ថវិកា | ទឹកប្រាក់(ដុល្លារអាម៉េរិក) |
|---|---|
| **ការិយាល័យគាំទ្ររបស់អង្គការ មូលនិធិហាកាអន្តរជាតិ** | |
| Hagar New Zealand | USD១៥៦,២៥០.00 |
| **ម្ចាស់ជំនួយផ្តល់មូលនិធិផ្ទាល់** | |
| MINISTRY OF FOREIGN AFFAIRS AND TRADE in New Zealand Aid Programme | USD៤៦៨,៧៥០.00 |
| សរុប | USD៦២៥,000.00 |

*គណនីប្រើប្រាស់ថវិកាខាងលើនៅក្នុងប្រទេសកម្ពុជា៖* ធនាគារ ANZ Royal Bank ដែលមានលេខគណនី២៨៦៨២៨

*ប្រភពថវិកា៖* ដែលបានផ្តល់ខាងលើត្រូវតែជាថវិកា ដើម្បីជួយដល់ក្រុមគោលដៅមនុស្សធម៌សុទ្ធសាធ គ្មានការពាក់ព័ន្ធទៅនឹងកិច្ចការយោធា នយោបាយ ឬសាសនាឡើយ ។

*ចំនួនបុគ្គលិកបរទេស៖* *គ្មាន*

*ចំនួនបុគ្គលិកខ្មែរ៖* *៤៣នាក់ (ស្រី២១នាក់ ប្រុស២២នាក់)*

*ចំនួនអ្នកទទួលផលសរុប៖* ដោយផ្ទាល់ចំនួន *២១០០ នាក់*

ដោយប្រយោលចំនួន *៣១០០ នាក់*

# ឧបសម្ពន្ធ(២)

## សកម្មភាពជាក់ស្ដែងរបស់អង្គការហោភាអន្តរជាតិ សហការជាមួយ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**១. គោលដៅកិច្ចសហប្រតិបត្តិការ៖**

ដោយផ្អែកលើបទពិសោធន៍សំខាន់ៗក្នុងរយៈពេល២៦ឆ្នាំកន្លងមកនេះ គម្រោងដែលនឹងអនុវត្តដោយ **អង្គការ មូលនិធិហោភាអន្តរជាតិ** តាមរយៈការផ្ដល់វគ្គបណ្តុះបណ្តាលផ្សេងៗ និងការរកការងារធ្វើសម្រាប់អតិថិជនដែលអត់ការងារធ្វើ និងផ្ដល់ការការពារផ្សេងៗ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយការកេងប្រវ័ញ្ចនានា និងធ្វើឲ្យកាន់តែប្រសើរឡើងនូវសមភាពយេនឌ័រ ដោយសហការជាមួយ និងអាជ្ញាធរដែលពាក់ព័ន្ធទាំងអស់ ។ អ្នកទទួលផលពីគម្រោងដែលជាជនរងគ្រោះពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ និងផលប៉ះពាល់បង្កឡើងដោយមេរោគកូវីដ១៩ ធ្វើឲ្យប៉ះពាល់ដល់ការរកប្រាក់ចំណូលរបស់គ្រួសារ និងហានិភ័យនៃការធ្វើចំណាកស្រុក ត្រូវបានកាត់បន្ថយតាម  រយៈការទទួលព័ត៌មានគ្រប់គ្រាន់ និងសេវាកម្មគាំទ្រនានា ។

**២. ពណ៌នាគម្រោងកម្មវិធី**

គម្រោង "**លើកកម្ពស់វិស័យសេដ្ឋកិច្ចសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ អំពើហិង្សាធ្ងន់ធ្ងរផ្អែកយេនឌ័រ និងពលករចំណាកស្រុកដែលបានធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ**" នឹងអនុវត្តនៅក្នុងខេត្តបាត់ដំបង, ខេត្តប៉ៃលិន, បន្ទាយមានជ័យ និងខេត្តសៀមរាប ដែលជាតំបន់មានចំនួនប្រជាកសិករចំណាកស្រុកច្រើន និងបានធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ ដោយសារពួកគេបានបាត់បង់ការងារ និងគ្មានប្រាក់ចំណូល ដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ ។

**៣. យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ**

- ពង្រឹងសមត្ថភាពអ្នកដឹកនាំក្រុមសហគមន៍មូលដ្ឋាន និងយន្តការដែលមានស្រាប់របស់រាជរដ្ឋាភិបាល និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធសំខាន់ៗនៅថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិក្នុងការបង្កើនការដោះស្រាយបញ្ហាអំពើហិង្សាប្រឆាំងនឹងស្ត្រី និងកុមារ កាត់បន្ថយការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ ។
- បង្កើនការទទួលបាននូវព័ត៌មាននានា ជាពិសេសចំពោះពលករចំណាកស្រុក និងសមាជិកសហគមន៍ ស្ដីពីការបង្ការការឆ្លងជំងឺកូវីដ១៩ ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព អំពើហិង្សាដោយផ្អែកលើយេនឌ័រការធ្វើចំណាកស្រុកដោយមានសុវត្ថិភាព ការការពារកុមារ យន្តការរាយការណ៍ និងការគាំទ្រដែលមានស្រាប់នៅក្នុងតំបន់ ដោយធ្វើការសហការជាមួយអ្នកទទួលខុសត្រូវក្នុងតំបន់ ស្ថាប័នពាក់ពន្ធ័ និងដៃគូអង្គការមិនមែនរដ្ឋាភិបាលនានា
- បង្កើនការទទួលបាននូវសេវាកម្មសមស្របដល់អ្នកទទួលផលពីគម្រោង ដូចជាការផ្ដល់សេវាប្រឹក្សា និងអប់រំផ្សព្វផ្សាយ ដើម្បីព្យាបាលការប៉ះទង្គិចផ្លូវចិត្ត និងកាត់បន្ថយនូវភាពតានតឹង និងថប់អារម្មណ៍ ដោយសារផលប៉ះពាល់នៃការរីករាលដោយជំងឺកូវីដ១៩
- បង្កើន និងពង្រឹងកិច្ចសហការ ជាមួយវិស័យឯកជន/និយោជក អាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្ដល់សេវាកម្មផ្សេងទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ/អ្នកទទួលផលរបស់គម្រោង
- លើកកម្ពស់អាជីវកម្មខ្នាតតូច និងបង្កើនលទ្ធភាពទទួលបានការងារធ្វើនៅក្នុងស្រុក សម្រាប់អ្នកទទួលផល ដើម្បីបង្កើនប្រាក់ចំណូល និងមានសន្តិសុខស្បៀង។

**៤. ផលប្រយោជន៍ដែលទទួលបានពីគម្រោងនេះរួមមាន៖**

**ក- ថែទាំក្នុងសហគមន៍៖**

- ជនរងគ្រោះទទួលបាននូវការថែទាំនៅក្នុងគ្រួសារបង្កើត គ្រួសារសាច់ញាតិ និងគ្រួសារចិញ្ចឹម ប្រកបដោយសុវត្ថិភាព ពីការរំលោភបំពាននានា ។
- ជនរងគ្រោះទទួលបានការជួយគាំទ្រ ក្នុងការថែទាំសុខភាព រួមទាំងការព្យាបាលជំងឺ ។
- ជនរងគ្រោះទទួលបានការជួយគាំទ្រស្បៀងអាហារ ទៅតាមតម្រូវការជាក់ស្ដែងដែលមានរយៈពេលកំណត់ ។
- ជនរងគ្រោះបន្ទាប់ពីបានស្តារនីតិសម្បទា ទទួលបានការគាំទ្រក្នុងការបន្តការរៀនសូត្រ ។
- ជនរងគ្រោះបន្ទាប់ពីបានស្តារនីតិសម្បទា មានជំនាញ និងអាចរកចំណូលដែលអាចរស់នៅដោយខ្លួនឯងបាន ។

- គ្រួសារជនរងគ្រោះទទួលបានជំនាញ និងអាចរកចំណូលក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន របស់ពួកគេដែលជាជនរងគ្រោះឲ្យរស់នៅដោយសុវត្ថិភាព និងមានការសិក្សាអប់រំ ។
- ជនរងគ្រោះបន្ទាប់ពីបានស្ដារនីតិសម្បទា ទទួលបានការជួយឧបត្ថមផ្នែកស្នាក់នៅក្នុងពេលកំពុងសិក្សារហូតដល់មហាវិទ្យាល័យ ដែលរស់នៅពាក់កណ្ដាលឯករាជ្យ មានបន្ទប់ ឬអន្តេវាសិកដ្ឋានស្នាក់នៅ មានសម្ភារដែលចាំបាច់សម្រាប់ការរស់នៅពាក់កណ្ដាលឯករាជ្យ ។
- មុនការធ្វើសមាហរណកម្ម ជនរងគ្រោះទទួលបានជំនួយបន្ទាន់ ដល់ឪពុកម្ដាយជនរងគ្រោះ ឬជនរងគ្រោះ ដូចជា អង្ករ ការជួសជុលផ្ទះ ការសាងសង់ផ្ទះ បង្គន់ និងកញ្ចប់ថវិកាក្នុងគ្រាចាំបាច់ទៅតាមតម្រូវការជាក់ស្ដែង និងធ្វើការតាមដានយ៉ាងទៀតទាត់រហូតដល់បិទករណី។
- ឪពុកម្ដាយរបស់ជនរងគ្រោះ ឪពុកម្ដាយចិញ្ចឹម សហគមន៍ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីសង្គមកិច្ច ចែករំលែកបទពិសោធន៍ពីរបៀបមើលថែកូន ការពារកូនឲ្យរស់នៅមានសុវត្ថិភាព និងសិទ្ធិរបស់កុមារ អំពើហិង្សាក្នុងគ្រួសារ ការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះ និងការជួញដូរមនុស្ស ។
- បុគ្គលិកអង្គការមូលនិធិហាការអន្តរជាតិ និងអង្គការដៃគូ យល់ដឹងពីការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះដែលមានបទពិសោធន៍ពីការរំលោភបំពាន ការយល់ដឹងពីសិទ្ធិ និងគោលការណ៍នៃការការពារកុមារ ។

**ខ- ផ្នែកស្ដារឡើងវិញពីការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ**

- ជនរងគ្រោះមានភាពជាសះស្បើយផ្នែករូបរាងកាយ អារម្មណ៍ ស្មារតី និងផ្លូវចិត្ត តាមរយៈការប្រឹក្សាយោបល់ ស៊ីជម្រៅ និងជាប្រព័ន្ធ។
- ជនរងគ្រោះមានទំនាក់ទំនងជាមួយសហគមន៍ គ្រួសារ និងសង្គម ។

**គ- ផ្នែកច្បាប់ និងការការពារ**

- ជនរងគ្រោះទទួលបានយុត្តិធម៌ពីការកាត់ទោសរបស់តុលាការជាតិ និងអន្តរជាតិ ។
- បុគ្គលិកអង្គការហាការ គ្រួសារចិញ្ចឹម អង្គការដៃគូ អាជ្ញាធរពាក់ព័ន្ធ មានការសហការកាន់តែប្រសើរក្នុងការការពារជនរងគ្រោះ។
- ជនរងគ្រោះមានសុវត្ថិភាព និងទទួលការថែទាំពីគ្រួសារបង្កើត សាច់ញាតិ និងគ្រួសារចិញ្ចឹមក្នុងសហគមន៍របស់ពួកគេ តាមរយៈកម្មវិធីថែទាំជំនួសរបស់អង្គការហាការ ។
- មេធាវីរបស់អង្គការហាការ អង្គការដៃគូ បុគ្គលិកសង្គមកិច្ចរបស់អង្គការ និងអ្នកដែលធ្វើការជាមួយជនរងគ្រោះមានចំណេះដឹងប្រសើរជាងមុន ទាក់ទងនឹងដំណើរការក្នុងការគាំទ្រជនរងគ្រោះក្នុងនីតិវិធីតុលាការ ។

**ឃ-** រដ្ឋអំណាចមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធសំខាន់ៗ នឹងមានការកើនឡើងនូវចំណេះដឹងនិងជំនាញក្នុងការឆ្លើយតបនឹងការជួញដូរនិងកេងប្រវ័ញ្ច អំពើហិង្សាផ្អែកលើយេនឌ័រ ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការការពារការឆ្លងរាលដាលនូវជំងឺកូវីដ១៩ ។

**ង-** អ្នកទទួលផលទូទៅពីគម្រោង មានការកើនឡើងនូវការយល់ដឹងលើការកែលម្អការថែទាំសុខភាពផ្លូវចិត្ត និងការការពារការឆ្លងរាលដាលនូវជំងឺកូវីដ១៩ និងសុវត្ថិភាពក្នុងការធ្វើចំណាកស្រុក ។

**ច-** ជនរងគ្រោះដែលជាស្ត្រី និងកុមារ ពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចគ្រប់ទម្រង់ និងអំពើហិង្សាធ្ងន់ធ្ងរផ្អែក យេនឌ័រ និងសុវត្ថិភាពក្នុងការធ្វើចំណាកស្រុក រួមទាំងសមាជិកគ្រួសាររបស់ពួកគេផងដែរ នឹងអាចទទួលបាននូវឱកាសបង្កើនសេដ្ឋកិច្ចគ្រួសាររបស់ពួកគេ ។

**ឆ-** សមាជិកសហគមន៍និងពលករចំណាកស្រុកមានការកើនឡើងនូវចំណេះដឹងស្ដីពីការជួញដូរ ការកេងប្រវ័ញ្ច ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការការពារការឆ្លងរាលដាលនូវជំងឺកូវីដ១៩ ។

**ជ-** ពលករចំណាកស្រុកដែលរងគ្រោះ នឹងទទួលបាននូវសេវាកម្មគាំទ្រ និងឱកាសបង្កើនសេដ្ឋកិច្ចគ្រួសារ ។

**ឈ-**ក្រុមកុមារ ស្ត្រី និងជនរងគ្រោះដែលជាពលករចំណាកស្រុកពីការជួញដូរ, ការកេងប្រវ័ញ្ច, និង អំពើហិង្សាធ្ងន់ធ្ងរផ្អែកយេនឌ័រ ដែលនឹងទទួលបានសេវាខាងលើ គឺជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការ រវាងអង្គការហាការ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) និងផ្នែកដែលពាក់ព័ន្ធផ្សេងទៀត ។

## ឧបសម្ព័ន្ធ(៣)

## លិខិតបទដ្ឋាន គតិយុត្ត និងគោលនយោបាយ ដែលអង្គការហោភារ ត្រូវប្រតិបត្តិ ៖

- អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារលេខ ១១៩.អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥
- គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ លេខ ៩០៧ ស.អ.យ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០៦
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារលេខ ២១៧ស.អ.យ ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០០៦ ។
- ប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល លេខ ៦១៦ ស.អ.យចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦។
- ប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ លេខ ១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែ មីនា ឆ្នាំ ២០០៨
- ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ លេខ ២២៨០ ស.អ.យ ចុះថ្ងៃ ទី១១ ខែតុលា ឆ្នាំ ២០១១
- ប្រកាសស្តីពីការទទួលស្គាល់គុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារលេខ ១៨០១ ស.អ.យ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១
- សារាចរណែនាំលេខ០០៩ ស.អ.យ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល
- ប្រកាសលេខ ៨៥២ ស.អ.យ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការដាក់ឲ្យអនុវត្តគោលនយោបាយស្តីអំពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ប្រកាសលេខ ៨៥៧ ស.អ.យ ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ឯកសារណែនាំស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាមឆ្នាំ២០១០
- នីតិវិធីប្រតិបត្តិបទដ្ឋានស្តីពីការផ្តល់ការគាំទ្រផ្នែកសមាហរណកម្មដល់ជនរងគ្រោះជាបុរសដោយអំពើជួញដូរមនុស្ស ខែឧសភា ឆ្នាំ២០១២
- ប្រកាសលេខ ១២៧៤ ស.អ.យ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល
- អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ ១១៦អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ
- ប្រកាសលេខ ២១៧៨ ស.អ.យ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការដាក់ឲ្យប្រើប្រាស់អនុវត្តឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ប្រកាសលេខ ១៣៣/១២ ប្រ.ក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ស្តីពីការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប។